ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០១១/២០ - ជីន យី ហ្គាមេន
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ **សេង រ៉ូចហ៊ិន**
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ **លីវ សុវណ្ណា**
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ **នុន សារ៉ាយ**

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិស្ពានពោធិ៍ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០១២ ៣២២ ២៦៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖
- លោក ឈួរ ហាំងហួត ប្រធានរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃ ក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា)**
អាសយដ្ឋាន ៖ ភូមិស្ពានពោធិ៍ ឃុំសេដ្ឋី ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
ទូរស័ព្ទ ៖ ០១១ ៥៤ ៤០ ៩៦ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ឈេន សំបូរ មេធាវី
២- លោកស្រី ម៉ន ចន្ធា មន្ត្រីសហព័ន្ធសហជីពកម្ពុជា
៣- លោក ហឿន ចាន់ថន ប្រធានសហជីព(សហជីពមូលដ្ឋាន)

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- កម្មករនិយោជិតនៅតែទាមទារឱ្យក្រុមហ៊ុនផ្តល់ប្រាក់ឈ្នួលមួយរយភាគរយ នៅអំឡុងពេលព្យួរការងារ តែភាគីក្រុមហ៊ុននៅតែឯកភាពអនុវត្តតាមការសម្រេចរបស់អង្គប្រជុំកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ហេតុដូច្នោះ ភាគីកម្មករនិយោជិតសុំឱ្យបញ្ជូនសំណុំរឿងទៅក្រុមប្រឹក្សាអាជ្ញាកណ្តាល។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨១ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៩ (អាណត្តិទី១៧)។ ការព្យាយាមផ្សះផ្សាវិវាទការងាររួមដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២(ក)នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមជីន ឃី ហ្គាមេន (ខេមបូឌា)លេខ ១០៩ ក.ប/កធ ចុះថ្ងៃចន្ទ ២រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣ ត្រូវនឹងថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ ត្រូវបាន បញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ១៣រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានទទួលលិខិតស្នើសុំឱ្យជួយដោះស្រាយវិវាទការងាររបស់ភាគីកម្មករនិយោជិត ស្តីពីការទាមទារឱ្យនិយោជកកែលំអលក្ខខណ្ឌការងារចំនួន ១ចំណុច។ បន្ទាប់ពីទទួលបានលិខិតស្នើសុំនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនោះជាបន្តបន្ទាប់ និងធ្វើការផ្សះផ្សាជាលើកចុងក្រោយ នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ចំណុចមិនសះជាចំនួន ១ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីន ឃី ហ្គាមេន (ខេមបូឌា) លេខ ១០៩ កប/កធ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត

មកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ១ចំណុចនេះ នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។ ដោយសារមានការស្នើសុំពន្យារពេលសវនាការពីភាគីកម្មករនិយោជិត និងមានការឯកភាពពីភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានសម្រេចលើកពេលសវនាការ ទៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង ២ និង ០០ នាទី រសៀល វិញ។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការតាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ និងបានធ្វើការផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ប៉ុន្តែ មិនទទួលបានលទ្ធផលសះជានឹងគ្នានោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទមិនសះជាចំនួន ១ចំណុចនេះ តែម្តង។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី២ ខែមីនា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរបានឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី១២ ខែមីនា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់ឈ្មោះ CHENG CHUN HUNG នាយកក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) សូមប្រគល់សិទ្ធិជូន លោក ឈួរ ហាំងហួត ជាប្រធានផ្នែកគ្រប់គ្រងរោងចក្រមានសិទ្ធិពេញលេញក្នុងការដោះស្រាយរាល់បញ្ហាវិវាទការងារ ក្នុងនាមតំណាងឱ្យម្ចាស់ ឬនាយកក្រុមហ៊ុន ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) លេខ MOC-៤០៧៩៩២៩៨ ពណ.ចបព ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។

៣- លក្ខន្តិកៈក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) បានតម្កល់ទុកលេខ ០២៦៩/២០១២ ពណ.ចបព ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា)។

៥- សេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) បានចុះបញ្ជីកាលេខ ៤៧៨ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ នៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង។

ARBITRATION COUNCIL

៦- កំណត់ហេតុប្រជុំស្តីពីការជូនដំណឹងដល់បងប្អូនកម្មករនិយោជិតនៃក្រុមហ៊ុនកាត់ដេរ ជីន យី (ខេមបូឌា) ខូ.,អិលធីឌី អំពីការផ្លាស់ប្តូរថ្ងៃបើកផ្តល់ប្រាក់ឈ្នួល ខែតុលា ឆ្នាំ២០១៩ ជូនកម្មករនិយោជិត ចុះថ្ងៃព្រហស្បតិ៍ ១១កើត ខែកត្តិក ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៩។

៧- កំណត់ហេតុប្រជុំស្តីពីការទូទាត់សំណងជូនកម្មករនិយោជិត ដែលក្រុមហ៊ុន ជីន យី (ខេមបូឌា) ខូ.,អិលធីឌី បញ្ចប់កិច្ចសន្យាការងារ ចុះថ្ងៃសៅរ៍ ៧រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២០។

៨- កំណត់ហេតុប្រជុំស្តីពីការពិភាក្សា អំពីលទ្ធភាពរបស់ក្រុមហ៊ុន ជីន យី (ខេមបូឌា) ខូ.,អិលធីឌី ក្នុងការបន្តដំណើរការ ឬមិនអាចបន្តដំណើរការបាន ចុះថ្ងៃសុក្រ ៩រោច ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៩។

៩- កំណត់ហេតុប្រជុំស្តីពីការប្រកាសពីលទ្ធភាពរបស់ក្រុមហ៊ុន ជីន យី (ខេមបូឌា) ខូ.,អិលធីឌី ក្នុងការបន្តដំណើរការ ឬមិនអាចបន្តដំណើរការបាន ចុះថ្ងៃចន្ទ ៥កើត ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖**

១- លិខិតតំណាងដោយអាណត្តិរបស់មេធាវី ឈេន សំបូរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីតំណាងដោយអាណត្តិឱ្យអាណត្តិទាយកឈ្មោះ ហឿន ចាន់ថន អត្តលេខ ១៦០៩១៥១០០២ ជាតំណាងសហជីពនៅក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០។

២- លិខិតប្រគល់សិទ្ធិតំណាងដោយអាណត្តិរបស់អាណត្តិទាយកឈ្មោះ ហឿន ចាន់ថន អត្តលេខ ១៦០៩១៥១០០២ ជាតំណាងសហជីពនៅក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) សូមប្រគល់សិទ្ធិជូនមេធាវី ឈេន សំបូរ ដើម្បីធ្វើជាតំណាងដោយអាណត្តិ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២០។

៣- ឯកសាររបស់មេធាវី ឈេន សំបូរ គោរពជូន ក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីដាក់សារណាការពារឱ្យអាណត្តិទាយកឈ្មោះ ហឿន ចាន់ថន អត្តលេខ ១៦០៩១៥១០០២ ជាតំណាងសហជីពនៅក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០។

៤- លិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចារ របស់កម្មករកម្មការិនី បម្រើការងារនៅក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) គោរពជូន ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកំពង់ឆ្នាំង ស្តីពីស្នើសុំជួយផ្សះផ្សាវិវាទការងារ រវាងយើងខ្ញុំ ជាមួយក្រុមហ៊ុន ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) លេខ ១០៩ កប/កឆ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) លេខ ០០១/២០ កប/កធ ល.ប.រ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២០ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកំពង់ឆ្នាំង។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៦០ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៦១ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ៥រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៦៨ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១១រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៦៩ កប/អក/វក/លកអ. ចុះថ្ងៃពុធ ១១រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣ ត្រូវនឹងថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២០។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា) គឺជាក្រុមហ៊ុនដែលមានសកម្មភាពចម្បងផ្នែកកាត់ដេរសម្លៀកបំពាក់ ទទួលបានវិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ ០០០១២១០០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១២។ ក្រុមហ៊ុននេះមានជួលកម្មករនិយោជិតសរុបចំនួន ១១៧៤ នាក់ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្នុងក្រុមហ៊ុន ជីន យី ហ្គាមេន (ខេមបូឌា))*
- យោងតាមលិខិតស្នើសុំ និងចាត់តាំងប្រតិភូចរចារបស់ភាគីកម្មករនិយោជិត ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០ បានបញ្ជាក់ឈ្មោះ និងស្នាមមេដៃកម្មករនិយោជិតដែលជាដើមបណ្តឹងចំនួន ៣០៧ នាក់ រួមជាមួយអ្នកតំណាងកម្មករនិយោជិតចំនួន ៥នាក់។ ហេតុនេះ ចំនួនកម្មករនិយោជិតដែលជាដើមបណ្តឹងសរុបចំនួន ៣១២នាក់។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលមួយរយភាគរយ នៅអំឡុងពេលព្យួរការងារ**

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោលចំនួន ១៩០ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃនិយោជកមានការងារ ឱ្យកម្មករនិយោជិតធ្វើធម្មតាវិញ។
- ភាគីទាំងពីរទទួលស្គាល់ថា ៖

- ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩ រហូតដល់បច្ចុប្បន្ន និយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើនោះទេ។
- នៅក្នុងខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០១៩ និយោជកបានព្យួរកិច្ចសន្យាការងារកម្មករនិយោជិតដោយមានលិខិតអនុញ្ញាតត្រឹមត្រូវពីអធិការការងារ។
- ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតមកដល់បច្ចុប្បន្ន (គឺថ្ងៃសវនាការទី២១ ខែកុម្ភៈ ឆ្នាំ២០២០) និយោជកមិនបានស្នើសុំបន្តព្យួរកិច្ចសន្យាការងារកម្មករនិយោជិតពីអធិការការងារទេ ហើយនិយោជកក៏មិនបានផ្តល់ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ ជូនកម្មករនិយោជិតនោះទេ។

- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតមកដល់ពេលបច្ចុប្បន្ន គឺមិនស្របតាមមាត្រា ៧១ នៃច្បាប់ស្តីពីការងារ។ ហេតុនេះ និយោជកត្រូវផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ជូនកម្មករនិយោជិត។
- ភាគីនិយោជករក្សាគោលជំហរមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មនិយោជិតបានទេ ដោយមូលហេតុថា ៖
  - ចាប់ពីខែមីនា ឆ្នាំ២០១៩មក ក្រុមហ៊ុនជួបវិបត្តិហិរញ្ញវត្ថុ ដោយហេតុថា មិនមានការបញ្ជាទិញ។ ហេតុនេះ និយោជកមិនមានលទ្ធភាពផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតនោះទេ។
  - យោងតាមកំណត់ហេតុប្រជុំ រវាងនិយោជក និងប្រធានសហជីពបានបញ្ជាក់ថា កម្មករនិយោជិតដែលស្ម័គ្រចិត្តរង់ចាំការងារ គឺមិនទាមទារអត្ថប្រយោជន៍ផ្សេងៗនោះទេ។ ហេតុនេះ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន និយោជកយល់ឃើញថា មិនមែនជាការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតនោះឡើយ។ ប៉ុន្តែ និយោជកយល់ឃើញថា ទំនាក់ទំនងរវាងនិយោជក និងកម្មករនិយោជិតនៅតែរក្សាដដែល។
  - លើសពីនេះទៀត និយោជកសង្ឃឹមថា នៅក្នុងខែមីនា ឆ្នាំ២០២០ ក្រុមហ៊ុននឹងមានដំណើរការធម្មតាវិញ។
- យោងតាមឯកសាររបស់ភាគីនិយោជក ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញ ៖ កំណត់ហេតុប្រជុំ ស្តីពីការប្រកាសលទ្ធផលរបស់ក្រុមហ៊ុន ជីន យី (ខេមបូឌា) ខូ., អិលធីឌី ក្នុងការបន្តដំណើរការ ឬមិនអាចបន្តដំណើរការបាន ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ កំណត់ថា ៖ *"ឃ. លទ្ធផលនៃកិច្ចប្រជុំ...៣-កម្មករនិយោជិតដែលមានបំណងរង់ចាំការងារនៅក្រុមហ៊ុន ជីន យី (ខេមបូឌា) ខូ.,អិលធីឌី ដោយមិនទាមទារប្រាក់អត្ថប្រយោជន៍ផ្សេងៗ ក៏ត្រូវមកចុះឈ្មោះនៅក្នុងក្រុមហ៊ុន ចាប់ពីថ្ងៃទី១១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២១ ខែមករា ឆ្នាំ២០២០។...។"*

## ហេតុផលនៃសេចក្តីសម្រេច ÷

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារ ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោលចំនួន ១៩០ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃនិយោជកមានការងារឱ្យកម្មករនិយោជិតធ្វើធម្មតាវិញ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលគោល ចំនួន ១៩០

ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតថ្ងៃនិយោជកមានការងារឱ្យកម្មករនិយោជិតធ្វើធម្មតាវិញដែរឬ ទេ?

ចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "*ពេលណាដែលសហគ្រាសជួបការលំបាកផ្នែកសេដ្ឋកិច្ច ឬសំភារៈធ្ងន់ធ្ងរ ឬការលំបាកជាពិសេសណាមួយដែលនាំឱ្យព្យួរសកម្មភាពសហគ្រាសមិនលើសពីពីរខែ។ ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ។*"

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ៥៨/០៧-៨ ស្តារ ស្តតវែរ ហេតុផលនៃចំណុចវិវាទទី១ បានបកស្រាយចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារខាងលើថា ៖ "*ការលំបាក ផ្នែកសំភារៈ ឬសេដ្ឋកិច្ចធ្ងន់ធ្ងរនេះ ជាហេតុផលដែលអាចអនុញ្ញាតឱ្យនិយោជកអាចព្យួរការងារ ប្រសិនបើនិយោជកបំពេញលក្ខខណ្ឌ ២ យ៉ាងគឺ ៖*

*- ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការកិច្ចការងារ និង*

*- ការព្យួរការងារនេះមិនត្រូវឱ្យលើសពី ២ខែ ។*"

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានបកស្រាយចំណុចទី១១ នៃមាត្រា ៧១ ថា ៖" *ការព្យួរសកម្មភាពនេះ ត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អធិការការងារ គឺមានន័យថា និយោជកត្រូវគោរពតាមកាតព្វកិច្ចនៃការជូនដំណឹង និងទទួលបានការអនុញ្ញាតជាមុនពីអធិការការងារ ទើបអាចព្យួរការងារដោយស្របច្បាប់បាន។*" (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៧២/០៥-ណាត ហ្គេអីធី ហេតុផលនៃចំណុចវិវាទទី១, លេខ ២២/០៥-អូសេអង់ ហេតុផលនៃចំណុចវិវាទទី២, លេខ ១៩៨/១៣-ស៊ូ អ៊ីកែរិល (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី២, លេខ ១៦០/១៤-អូសេអង់ ហ្គាមិន ខូអិលធីឌី, លេខ ០៨/០៧-ស៊ាវគីញ ចំណុចវិវាទទី២ និងលេខ ០០៨/១៧-ថបរើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី ចំណុច វិវាទទី១*)

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

យោងតាមអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា ចាប់ពីខែវិច្ឆិកា ឆ្នាំ២០១៩ រហូតមកដល់បច្ចុប្បន្ននិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើនោះទេ ដោយមូលហេតុថា ក្រុមហ៊ុនមិនមានការបញ្ជាទិញ។ ម្យ៉ាងទៀត ចាប់ពីខែមករា ឆ្នាំ២០២០ រហូតដល់បច្ចុប្បន្ន និយោជកមិនបានស្នើសុំអនុញ្ញាតការព្យួរកិច្ចសន្យាការងារពីអធិការការងារ ហើយនិយោជកក៏មិនបានផ្តល់ប្រាក់ឈ្នួលជូនកម្មករនិយោជិតផងដែរ។ យោងតាមអង្គហេតុ និងការបកស្រាយចំណុចទី១១ មាត្រា ៧១ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ករណីដែលនិយោជកមិនមានការងារឱ្យកម្មករនិយោជិតធ្វើនៅពេលដែលក្រុមហ៊ុនមិនមានការបញ្ជាទិញនេះ គឺជាការព្យួរកិច្ចសន្យាការងារកម្មករនិយោជិត។

លើសពីនេះ ចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ "*ការព្យួរកិច្ចសន្យាការងារនាំឱ្យប៉ះពាល់តែកាតព្វកិច្ចសំខាន់ៗ នៃកិច្ចសន្យាការងារ ពោលគឺកាតព្វកិច្ចដែលកម្មករនិយោជិតត្រូវធ្វើការឱ្យនិយោជក និងកាតព្វកិច្ចដែលនិយោជកត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករនិយោជិត លើកលែងតែមានបទប្បញ្ញត្តិផ្ទុយ ដែលកំណត់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិត ។*"

ផ្អែកតាមចំណុចទី១ មាត្រា ៧២ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថានិយោជកមិនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួលឱ្យកម្មករនិយោជិតទេ នៅពេលមានការព្យួរកិច្ចសន្យាការងារ ប៉ុន្តែ

ចំណុចទី១ នៃមាត្រា ៧២ ខាងលើ ត្រូវបានអនុវត្តនៅពេលដែលការព្យួរកិច្ចសន្យាការងារធ្វើឡើងដោយស្រប តាមនីតិវិធីច្បាប់ប៉ុណ្ណោះ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ៖ *"ប្រសិនបើ ក្រុមហ៊ុនបានធ្វើបែបបទព្យួរការងារត្រឹមត្រូវតាមច្បាប់ស្តីពីការងារ ដោយការព្យួរកិច្ចសន្យាការងារនោះ ត្រូវបាន ស្ថិតនៅក្រោមការត្រួតពិនិត្យពីអធិការកិច្ចការងារនោះ ក្រុមហ៊ុនមិនមានកាតព្វកិច្ចត្រូវផ្តល់ប្រាក់ឈ្នួលដល់កម្មករ និយោជិតឡើយ។ ប៉ុន្តែ ប្រសិនបើក្រុមហ៊ុនមិនបានគោរពតាមច្បាប់ស្តីពីការងារ នៃការព្យួរកិច្ចសន្យាការងារ កម្មករនិយោជិត ដូចបានរៀបរាប់ខាងលើទេនោះ ក្រុមហ៊ុនមានកាតព្វកិច្ចផ្តល់ប្រាក់ឈ្នួល ១០០ភាគរយ ព្រមទាំងអត្ថប្រយោជន៍ផ្សេងៗ ដល់កម្មករនិយោជិត ទោះបីជាក្រុមហ៊ុនពុំមានការងារឱ្យកម្មករនិយោជិតធ្វើក៏ ដោយ។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២១/០៣-ឡយ អ័ល ខេមបូឌា ហេតុផលនៃចំណុច វិវាទទី៨, លេខ ០១/០៤-ញូវ កាញ់ ២, លេខ ៦០/០៦-ញូវមេក ហ្គាមេន ហេតុផលនៃចំណុចវិវាទទី២, លេខ ៧៤/០៧-ក្លូបល អាប៉ារ៉ែល ហេតុផលនៃចំណុចវិវាទទី១, លេខ ២៧/០៨-អាក យីត ហេតុផលនៃចំណុចវិវាទ ទី៦, លេខ ១០៩/០៩-យូ អេស អេ ហេតុផលនៃចំណុចវិវាទទី៤ និងលេខ ០០៨/១៧-ថបវើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី ចំណុចវិវាទទី១)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របចំពោះការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

តាមរយៈអង្គហេតុ ភាគីទាំងពីរទទួលស្គាល់ថា ចំពោះរយៈពេលដែលមិនមានការងារធ្វើ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតមកដល់បច្ចុប្បន្ននេះ និយោជកមិនបានស្នើសុំព្យួរកិច្ចសន្យាការងារកម្មករនិយោជិត ទៅអធិការការងារស្របតាមនីតិវិធីច្បាប់នោះទេ។ ដោយភាគីនិយោជកគ្រាន់តែយោងទៅតាមកំណត់ហេតុនៃ ការប្រជុំកាលពីថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០១៩ ដែលកំណត់ថា កម្មករនិយោជិតដែលសម្រេចចុះឈ្មោះរង់ចាំការងារ នៅក្នុងក្រុមហ៊ុន គឺមិនទាមទារប្រាក់អត្ថប្រយោជន៍ផ្សេងៗ នោះទេ។

យោងតាមកំណត់ហេតុនៃការប្រជុំ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ជាកំណត់ហេតុនេះ គឺទាក់ទង និងអត្ថប្រយោជន៍ផ្សេងៗ ពោលគឺមិនពាក់ព័ន្ធជាមួយជាការទាមទារលើប្រាក់ឈ្នួលគោល ជូនកម្មករនិយោជិត នោះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនពិចារណាលើកំណត់ហេតុនៃការប្រជុំនោះទេ។

លើសពីនេះទៀត យោងតាមមាត្រា ៧១ និង មាត្រា ៧២ នៃច្បាប់ស្តីពីការងារខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលរកឃើញថា និយោជកព្យួរកិច្ចសន្យាការងារកម្មករនិយោជិតនេះ គឺធ្វើឡើងដោយមិនត្រឹមត្រូវតាម នីតិវិធីច្បាប់នោះទេ។ ហេតុនេះ និយោជកមានកាតព្វកិច្ចក្នុងការផ្តល់ប្រាក់ឈ្នួលគោលចំនួន ១៩០ ដុល្លារ-អាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិតចំពោះរយៈពេលដែលមិនមានការងារធ្វើ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃនិយោជកមានការងារឱ្យកម្មករនិយោជិតធ្វើជម្មតាវិញ។

ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកផ្តល់ប្រាក់ឈ្នួលគោលចំនួន ១៩០ដុល្លារ អាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃនិយោជកមានការងារ ឱ្យកម្មករនិយោជិតធ្វើជម្មតាវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

- បង្គាប់ឱ្យនិយោជកផ្ដល់ប្រាក់ឈ្នួលគោលចំនួន ១៩០ដុល្លារអាមេរិក ក្នុងមួយខែ ជូនកម្មករនិយោជិត ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២០ រហូតដល់ថ្ងៃនិយោជកមានការងារឱ្យកម្មករនិយោជិតធ្វើធម្មតាវិញ។

**ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ចំនួន០៨ ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **សេង ឡុចហ៊ុន**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីម សុវណ្ណា**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្ដាល ៖

ឈ្មោះ ៖ **រុន សារ៉ាយ**

ហត្ថលេខា ៖ ------------------------------

ARBITRATION COUNCIL